

# ច្បាប់ CARE

## ច្បាប់ ស្ដីពី ជំនួយសហគមន៍, ការស្តារឡើងវិញ និង ការផ្តល់សិទ្ធិអំណាច

### សេចក្ដីសង្ខេប អំពី ច្បាប់ CARE

ច្បាប់ ស្ដីពី ជំនួយសហគមន៍ ការស្តារឡើងវិញ និងការផ្តល់សិទ្ធិអំណាច (CARE) គឺជាដំណើរការនីតិវិធីតុលាការស៊ីវិលថ្មីមួយ ដែលផ្តល់សេវាកម្មផ្សេងៗដល់អ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្តមួយចំនួន និងបានបំពេញតាមលក្ខណៈវិនិច្ឆ័យ។ ច្បាប់ CARE អនុញ្ញាតឱ្យបុគ្គលមួយចំនួន (ដែលគេស្គាល់ថា "អ្នកដាក់ញត្តិ") ដើម្បីស្នើសុំឱ្យនរណាម្នាក់ចូលរួមក្នុងដំណើរការនីតិវិធី CARE។ ដំណើរការនីតិវិធី CARE រួមមានការវាយតម្លៃ និងអង្គសវនាការដើម្បីសម្រេចថាតើបុគ្គលដែលគេហៅថា "អ្នកឆ្លើយតប" មានសិទ្ធិទទួលបានឬអត់។ ប្រសិនបើអ្នកឆ្លើយតបមានសិទ្ធិទទួលបាន កិច្ចព្រមព្រៀង CARE ដោយស្ម័គ្រចិត្ត ឬ គម្រោង CARE ដែលត្រូវបានចេញដីកាបង្គាប់ដោយតុលាការអាចត្រូវបានបង្កើតឡើងរហូតដល់ទៅរយៈពេល 12 ខែ ដោយមានលទ្ធភាពបន្តបន្ថែមរយៈពេល 12 ខែទៀត។ កិច្ចព្រមព្រៀង ឬគម្រោងនេះរួមមានសេវាកម្មផ្សេងៗដែលបុគ្គលអាចទទួលបាន ដូចជាសេវាសុខភាពផ្នែកអាកប្បកិរិយា ការព្យាបាលបញ្ហាការប្រើប្រាស់សារធាតុញៀន លំនៅឋាន និងការជួយគាំទ្រសហគមន៍។

## វិធីចូលរួម

វិធី**ចូលរួម**សម្រាប់អ្នកមានសិទ្ធិទទួលបានដែលមានជំងឺផ្លូវចិត្តដែលបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសុខភាព និងសុវត្ថិភាព។ មនុស្សជាច្រើនអាចណែនាំអ្នកដទៃដើម្បីទទួលជំនួយនេះ។

- គ្រួសារ
- អ្នកផ្តល់សេវាថែទាំសុខភាព
- សុខភាពផ្លូវចិត្តតាមខោនធី
- អ្នកឆ្លើយតបដំបូង
- អ្នកផ្តល់សេវាសង្គម

## ដំណើរការនីតិវិធី CARE

ដំណើរការនីតិវិធីតុលាការថ្មី ដើម្បី **តភ្ជាប់និងកំណត់អាទិភាព** លើការព្យាបាល សេវាជួយគាំទ្រនានា និងលំនៅឋាន។

## វិធីបញ្ចប់

មានវិធីជាច្រើនដើម្បី**ចាកចេញ**ពីដំណើរការនីតិវិធី នេះ។

ការចូលរួមដំបូង នៅក្នុង សេវាកម្មព្យាបាល តាមខោនធី។

ការបញ្ចប់ពី **កិច្ចព្រមព្រៀង CARE** ឬ **គម្រោង CARE**។

## ជំនួយនៅតែបន្ត

**នៅចុងបញ្ចប់**នៃដំណើរការនីតិវិធី ជំនួយនៅតែបន្ត។

សេវាកម្មតាមខោនធី ផ្ទាល់ អាច នៅតែបន្ត តាមការចាំបាច់។

DHCS
CALIFORNIA DEPARTMENT OF HEALTH CARE SERVICES

# តើអ្នកណាខ្លះមានសិទ្ធិទទួលបាន គម្រោង CARE?

> ភាពគ្មានផ្ទះសម្បែង និង ជំងឺផ្លូវចិត្តតែមួយមុខមិនគ្រប់គ្រាន់ដើម្បីបំពេញទៅតាមតម្រូវការសិទ្ធិទទួលបាននោះទេ។

សិទ្ធិទទួលបានត្រូវបានកំណត់ទៅតាមសំណុំរឿងនីមួយៗ។ ភាពគ្មានផ្ទះសម្បែង និងជំងឺផ្លូវចិត្តតែមួយមុខមិនគ្រប់គ្រាន់ដើម្បីបំពេញទៅតាមតម្រូវការសិទ្ធិទទួលបាននោះទេ។

អ្នកឆ្លើយតបត្រូវតែបំពេញទៅតាមលក្ខណៈវិនិច្ឆ័យខាងក្រោមទាំងអស់ ដើម្បីមានសិទ្ធិទទួលបាន CARE៖

- ត្រូវមានអាយុចាប់ពី 18 ឆ្នាំ ឡើងទៅ។
- មានការធ្វើរោគវិនិច្ឆ័យនៃចង្កោមជំងឺផ្លូវចិត្តដែលទាក់ទងនឹងសង្គម ឬជំងឺផ្លូវចិត្តមួយផ្សេងទៀតនៅក្នុងកម្រិតដូចគ្នា។
- បច្ចុប្បន្នកំពុងមានជំងឺផ្លូវចិត្ត៖
    - ក្នុងកម្រិតធ្ងន់ធ្ងរ និងជាប់លាប់ក្នុងរយៈពេលមួយ,
    - អាចបណ្ដាលឱ្យមានអាកប្បកិរិយាដែលមានការរំខានយ៉ាងខ្លាំងដល់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និង
    - អាចបណ្ដាលឱ្យមានអសមត្ថភាពក្នុងការរក្សាការកែតម្រូវប្រកបដោយស្ថេរភាព និងដំណើរការដោយឯករាជ្យ បើគ្មានការព្យាបាល ការជួយគាំទ្រ និងការស្ដារនីតិសម្បទារយៈពេលវែង ឬរយៈពេលមិនកំណត់ទេ។
- មិនសម្រេចបាននូវស្ថេរភាពព្យាបាល ទោះបីជាមានការព្យាបាលដោយស្ម័គ្រចិត្តកំពុងបន្តក៏ដោយ។

លើសពីនេះទៀត យ៉ាងហោចណាស់លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវតែបំពេញតាម៖

- អ្នកឆ្លើយតបទំនងជាមិនអាចរស់នៅបានដោយសុវត្ថិភាពនៅក្នុងសហគមន៍ដោយគ្មានការត្រួតពិនិត្យទេ **ហើយ**ស្ថានភាពរបស់អ្នកឆ្លើយតបកាន់តែយ៉ាប់យ៉ឺនខ្លាំងទៅ។
- អ្នកឆ្លើយតបត្រូវការសេវាកម្ម និងការជួយគាំទ្រ ដើម្បីការពារការលាប់ឡើងវិញ ឬការចុះខ្សោយ ដែលអាចបណ្ដាលឱ្យមានពិការភាពធ្ងន់ធ្ងរ ឬមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អ្នកឆ្លើយតប ឬអ្នកដទៃ។

ការចូលរួមរបស់អ្នកឆ្លើយតបនៅក្នុងគម្រោង CARE ឬកិច្ចព្រមព្រៀង CARE ត្រូវតែ៖

- ជាជម្រើសដែលមានការរិតបន្តឹងតិចបំផុតដែលត្រូវការដើម្បីធានាដល់ការជួយគាំទ្រដល់ការស្ដារឡើងវិញ និងស្ថិរភាពរបស់អ្នកឆ្លើយតប **និង**
- អាចផ្ដល់អត្ថប្រយោជន៍ដល់អ្នកឆ្លើយតប។

អ្នកដាក់ញត្តិត្រូវផ្ដល់ព័ត៌មានពិត និងព័ត៌មានគាំទ្រនៅពេលដាក់ឯកសារ ដើម្បីបង្ហាញថាអ្នកឆ្លើយតបមានសិទ្ធិទទួលបានសម្រាប់ដំណើរការនីតិវិធី CARE (សូមមើលទម្រង់បែបបទ CARE-050-INFO)។ ឯកសារគាំទ្រត្រូវតែមានទាំង សេចក្ដីប្រកាសដោយអ្នកជំនាញសុខភាពផ្នែកអាកប្បកិរិយាដែលមានអាជ្ញាបណ្ណ (ទម្រង់បែបបទ CARE-101) ឬភស្តុតាងដែលថាអ្នកឆ្លើយតបត្រូវបានឃុំឃាំងខ្លួនសម្រាប់ការព្យាបាលបែបស៊ីជម្រៅជាអប្បបរមាចំនួនពីរដង ដោយការព្យាបាលលើកចុងក្រោយបំផុតបានធ្វើឡើងក្នុងរយៈពេល 60 ថ្ងៃចុងក្រោយ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលតារាងអង្គហេតុសិទ្ធិទទួលបាន និងធនធានច្បាប់ CARE សម្រាប់អ្នកដាក់ញត្តិ។

# អ្នកណាខ្លះអាចដាក់ញត្តិបាន?

អ្នកដាក់ញត្តិត្រូវមានអាយុចាប់ពី 18 ឆ្នាំ ឬច្រើនជាងនេះ ហើយឆ្លើយតបទៅនឹងប្រភេទមួយក្នុងចំណោមប្រភេទទាំងអស់ខាងក្រោម៖

- ជាអ្នកដែលរស់នៅជាមួយនឹងអ្នកឆ្លើយតប។
- ជាប្តីប្រពន្ធ ឬដៃគូគ្រួសារដែលបានចុះបញ្ជី ឪពុកម្តាយ បងប្អូនបង្កើត កូន ឬជីដូនជីតារបស់អ្នកឆ្លើយតប។
- រូបវន្តបុគ្គលដែលដើរតួជាឪពុកម្តាយរបស់អ្នកឆ្លើយ។
- ប្រធានមន្ទីរពេទ្យ ឬអ្នកចាត់តាំងរបស់ពួកគេ ដែលអ្នកឆ្លើយតប កំពុងសម្រាកព្យាបាល ឬបានសម្រាកព្យាបាលនៅមន្ទីរពេទ្យថ្មីៗនេះ។
- នាយកភ្នាក់ងារសាធារណៈ ឬអង្គការសប្បុរសធម៌ ឬអ្នកចាត់តាំងរបស់ពួកគេដែលបានផ្តល់ ឬកំពុងផ្តល់សេវាសុខភាពផ្នែកអាកប្បកិរិយាដល់អ្នកឆ្លើយតបក្នុងរយៈពេល 30 ថ្ងៃចុងក្រោយ ឬនៅក្នុងទីកន្លែងដែលអ្នកឆ្លើយតបកំពុងរស់នៅ។
- អ្នកជំនាញសុខភាពផ្នែកអាកប្បកិរិយាដែលមានអាជ្ញាបណ្ណ ឬអ្នកចាត់តាំងរបស់ពួកគេ ដែលកំពុងគ្រប់គ្រង ឬបានគ្រប់គ្រងការព្យាបាល ឬព្យាបាលអ្នកឆ្លើយតបចំពោះជំងឺផ្លូវចិត្តក្នុងរយៈពេល 30 ថ្ងៃចុងក្រោយ។
- ប្រធានភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយាប្រចាំខោនធី ឬអ្នកចាត់តាំងរបស់ពួកគេនៃខោនធីដែលអ្នកឆ្លើយតបកំពុងរស់នៅ ឬស្ថិតនៅ។
- អ្នកឆ្លើយតបដំបូងដែលមានអន្តរកម្មជាប់ជាប្រចាំជាមួយនឹងអ្នកឆ្លើយតប។
- ចៅក្រមនៃតុលាការកុលសម្ព័ន្ធដែលមានទីតាំងនៅរដ្ឋកាលីហ្វ័រញ៉ា ឬអ្នកចាត់តាំងរបស់ពួកគេ។
- អ្នកឆ្លើយតប។

ចំណាំ៖ បន្ទាប់ពីការបង្ហាញខ្លួននៅសវនាការដំបូង អ្នកដាក់ញត្តិដើមដំបូងនឹងត្រូវបានជំនួសដោយប្រធានភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី ឬអ្នកចាត់តាំង។

សម្រាប់ព័ត៌មានបន្ថែម សូមមើលធនធានច្បាប់ CARE សម្រាប់អ្នកដាក់ញត្តិ។



## តើមានអ្វីកើតឡើងក្នុងអំឡុងពេលដំណើរការនីតិវិធី CARE?

នៅពេលដាក់ញត្តិសំរួច តុលាការនឹងពិនិត្យពិចារណាលើញត្តិដើម្បីសម្រេចថាតើអ្នកឆ្លើយតប បំពេញតាម ឬអាចបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់គម្រោង CAREដែរឬអត់។ បន្ទាប់មក តុលាការអាចនឹងច្រានចោលញត្តិនេះ ចេញដីកាឱ្យយករបាយការណ៍ពីភ្នាក់ងារសុខភាពផ្លូវចិត្តអាកប្បកិរិយារបស់ខោនធី ឬកំណត់ពេលសវនាការដំបូងនៅតុលាការ។

ប្រសិនបើអ្នកឆ្លើយតបត្រូវបានរកឃើញថាមានសិទ្ធិទទួល តុលាការនឹងធ្វើការជាមួយភ្នាក់ងារសុខភាពផ្លូវចិត្តអាកប្បកិរិយាខោនធី អ្នកឆ្លើយតប មេធាវីរបស់អ្នកឆ្លើយតប និងជំនួយការស្ម័គ្រចិត្ត (ប្រសិនបើមាន) ដើម្បីភ្ជាប់អ្នកឆ្លើយតបជាមួយនឹងសេវាកម្មផ្សេងៗ។ ការតភ្ជាប់នេះនឹងកើតឡើងតាមរយៈការចូលរួមដោយស្ម័គ្រចិត្ត កិច្ចព្រមព្រៀង CARE ឬគម្រោង CARE។

ប្រសិនបើកិច្ចព្រមព្រៀង CARE មិនត្រូវបានសម្រេចទេ នោះនឹងមានការវាយតម្លៃការព្យាបាល។ ប្រសិនបើការវាយតម្លៃការព្យាបាលនេះរកឃើញថាអ្នកឆ្លើយតប មានសិទ្ធិទទួល តុលាការនឹងចេញដីកាបង្គាប់ឱ្យអនុវត្តគម្រោង CARE។ នឹងមានអង្គសវនាការពិនិត្យស្ថានភាពជាបន្តបន្ទាប់ នៅពេលដែលអ្នកឆ្លើយតបកំពុងទទួលបានសេវាកម្មតាមរយៈគម្រោង CAREនេះ។

នៅខែទី 11 នឹងមានសវនាការពិនិត្យស្ថានភាពរយៈពេល 1 ឆ្នាំ ដើម្បីសម្រេចទៅលើជំហានបន្ទាប់ដែលត្រូវអនុវត្តបន្ត។ អ្នកចូលរួមអាចបញ្ចប់គម្រោង ឬត្រូវបានផ្តល់បន្តរហូតដល់ 1 ឆ្នាំបន្ថែមទៀត។ បន្ទាប់ពីបានបញ្ចប់គម្រោងពីដំណើរការនីតិវិធី CARE អ្នកចូលរួមនៅតែមានសិទ្ធិទទួលបានការព្យាបាលបន្ត សេវាជួយគាំទ្រ និងលំនៅឋាននៅក្នុងសហគមន៍ ដើម្បីជួយគាំទ្រដល់ការស្តារឡើងវិញរយៈពេលវែង។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីដំណើរការនីតិវិធី CARE សូមមើល លំហូរដំណើរការនីតិវិធី CARE ចំពោះការព្យាបាល លំនៅឋាន និងការជួយគាំទ្រ។

## តើកិច្ចព្រមព្រៀង CARE ឬគម្រោង CARE ជាអ្វី?

កិច្ចព្រមព្រៀង CARE និងគម្រោង CARE គឺជាឯកសារដែលបញ្ជាក់ពីសេវាកម្មផ្សេងៗដើម្បីជួយគាំទ្រដល់ការស្តារឡើងវិញ និងស្ថេរភាពរបស់អ្នកឆ្លើយតប។

កិច្ចព្រមព្រៀង CARE គឺជាកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្តរវាងអ្នកឆ្លើយតប និងភ្នាក់ងារសុខភាពផ្លូវចិត្តអាកប្បកិរិយារបស់ខោនធី បន្ទាប់ពីតុលាការបានសម្រេចថាអ្នកឆ្លើយតបមានសិទ្ធិទទួលសម្រាប់ដំណើរការនីតិវិធី CARE។ ប្រសិនបើកិច្ចព្រមព្រៀង CARE មិនត្រូវបានសម្រេចទេ តុលាការអាចចេញដីកាឱ្យបង្កើតគម្រោង CARE។

គម្រោង CARE រួមមានសេវាកម្មផ្សេងៗ និងការជួយគាំទ្រសហគមន៍ជាច្រើនដែលចេញដីកាបង្គាប់ដោយតុលាការ។ នឹងមានអង្គសវនាការពិនិត្យស្ថានភាពដើម្បីពិនិត្យមើលពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា។ សេវាកម្ម និងជំនួយនៅក្នុងគម្រោង CARE អាចត្រូវបានផ្លាស់ប្តូរដើម្បីជួយគាំទ្រដល់ភាពជោគជ័យរបស់អ្នកឆ្លើយតប។

ប្រសិនបើអ្នកត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោង ឬកិច្ចព្រមព្រៀង CARE អ្នកផ្តល់សេវាថែទាំសុខភាពផ្លូវចិត្តអាកប្បកិរិយាដែលមានអាជ្ញាបណ្ណព្យាបាលនឹងចេញវេជ្ជបញ្ជាថ្នាំឱសថដើម្បីធ្វើឱ្យមានស្ថេរភាព។ ក្រុមការងារ គម្រោង CARE នឹងធ្វើការជាមួយអ្នកឆ្លើយតប ដើម្បីដោះស្រាយកង្វល់អំពីការផ្តល់ឱសថ និងធ្វើការផ្លាស់ប្តូរផែនការព្យាបាលតាមតម្រូវការ។

## តើលំនៅឋានបែបណាដែលអាចរកបានសម្រាប់អ្នកឆ្លើយតបនៅក្នុងគម្រោង CARE?

លំនៅឋានគឺជាផ្នែកដ៏សំខាន់មួយនៃ គម្រោង CARE។ ជម្រើសលំនៅឋានរួមមាន៖

- លំនៅឋានបណ្ដោះអាសន្ន ឬអន្តរកាល ដោយមានការជួយគាំទ្រកែលម្អផ្នែកការព្យាបាល
- កន្លែងថែទាំមនុស្សពេញវ័យ និងមនុស្សចាស់ដែលមានអាជ្ញាបណ្ណ
- លំនៅឋានដែលមានការជួយគាំទ្រ
- លំនៅឋានជាមួយគ្រួសារ និងមិត្តភក្តិ

ដើម្បីជួយផ្គត់ផ្គង់តម្រូវការលំនៅឋានរបស់អ្នកឆ្លើយតប តុលាការអាចចេញដីកាបង្គាប់ឱ្យផ្ដល់អាទិភាពសម្រាប់សេវាកម្ម និងជំនួយទាំងនេះ។

## តើសេវាកម្ម ច្បាប់ CARE នឹងមាននៅពេលណា?

ច្បាប់ CARE កំពុងត្រូវបានអនុវត្តជាពីរដំណាក់កាល។ ខោនធី Glenn Orange Riverside San Diego Stanislaus Tuolumne និង San Francisco (Cohort I) បានអនុវត្តច្បាប់ CARE នៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2023។ ខោនធី Los Angeles គ្រោងនឹងអនុវត្តត្រឹមថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2023 ហើយគ្រប់ខោនធីផ្សេងទៀត (Cohort II) ត្រូវបានតម្រូវឱ្យអនុវត្តច្បាប់ CARE ត្រឹមថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2024។

## តើគម្រោង CARE អាចធានាបាននូវគណនេយ្យភាពដោយរបៀបណា?

គណនេយ្យភាពក្នុងគម្រោង CARE មានពីរវិធី។ ប្រសិនបើអ្នកឆ្លើយតបមិនអាចបំពេញតាមគម្រោង ដោយជោគជ័យបានទេ តុលាការអាចប្រើប្រាស់ច្បាប់ដែលមានស្រាប់ ដើម្បីធានាសុវត្ថិភាពរបស់ពួកគេ។ ច្បាប់ CARE ក៏ធានាឱ្យរដ្ឋាភិបាលមូលដ្ឋានមានគណនេយ្យភាពផងដែរ។ ប្រសិនបើពួកគេមិនបំពេញតាមទំនួលខុសត្រូវរបស់ពួកគេក្រោម គម្រោង CARE ទេ ពួកគេអាចនឹងត្រូវបានផាកពិន័យ។



## តើអ្នកឆ្លើយតបមានសិទ្ធិអ្វីខ្លះ?

ច្បាប់ CARE ជួយគាំទ្រដល់មាគ៌ាស្វ័យសម្រេចដើម្បីស្តារឡើងវិញ។ អ្នកឆ្លើយតបមានសិទ្ធិ៖

- ទទួលបានព័ត៌មានអំពីដំណើរការនីតិវិធី។
- ចូលរួមក្នុងដំណើរការនីតិវិធី។
- មានមេធាវីតំណាងនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។
- ទទួលបានមេធាវីថ្មីដែលត្រូវបានតែងតាំងដោយតុលាការ (ផ្តល់ជូនដោយឥតគិតថ្លៃ) ជាមួយនឹងមេធាវីដែលពួកគេជ្រើសរើស។
- ទទួលបានច្បាប់ចម្លងនៃញត្តិ និងការវាយតម្លៃ ឬរបាយការណ៍ដែលចេញដីកាបង្គាប់ដោយតុលាការ។
- មានជំនួយការស្ម័គ្រចិត្ត ១រូប ដោយការជ្រើសរើសរបស់ពួកគេពេញមួយដំណើរការនីតិវិធី។

ប្រសិនបើអ្នកឆ្លើយតបទាមទារឱ្យមានការបកប្រែ ឬជំនួយសម្រាប់ពិការភាព សំណើអាចធ្វើឡើងជាមួយនឹងតុលាការ។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពី ច្បាប់ CARE នៅឯណាបាន?

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ មជ្ឈមណ្ឌលធនធាន ច្បាប់ CARE គេហទំព័រ DHCS ច្បាប់ CARE គេហទំព័រ CalHHS ច្បាប់ CARE និងគេហទំព័រ ច្បាប់ CARE របស់ក្រុមប្រឹក្សាតុលាការ។ អ្នកក៏អាចផ្ញើសារទៅកាន់ info@CARE-Act.org ដើម្បីស្នើសុំព័ត៌មានបន្ថែម។

## ការដកស្រង់លក្ខន្តិកៈ

- **និយមន័យ៖** ក្រមសុខុមាលភាព និងស្ថាប័នរដ្ឋកាលីហ្វ័រញ៉ា (ក្រម W&I ) ផ្នែក 5971
- **សិទ្ធិទទួលបាន៖** ក្រម W&I ផ្នែក 5972
- **ការដាក់ញត្តិ** ក្រម W&I ផ្នែក 5974 និង 5975
- **សិទ្ធិអ្នកឆ្លើយតប** ក្រម W&I ផ្នែក 5976, 5976.5, 5977.2, និង 5977.3
- **ដំណើរការនីតិវិធីតុលាការ** ក្រម W&I ផ្នែក 5977, 5977.1, 5977.2, និង 5977.3
- **សេវាកម្មផ្សេងៗ៖** ក្រម W&I ផ្នែក 5977.1
- **ការរក្សាការសម្ងាត់៖** ក្រម W&I ផ្នែក 5976.5, 5977.1(c)(5), និង 5977.4